D119819 DC-Cam

# របាយការណ៍
# ស្តីពីការចុះស្រាវជ្រាវ និងធ្វើផែនទី
# រណ្តៅសាកសពជនរងគ្រោះដោយ
# របបខ្មែរក្រហម ប្រល័យពូជសាសន៍
# នៅខេត្តតាកែវ

កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៨ មជ្ឈមណ្ឌលស្រាវជ្រាវឯកសារកម្ពុជា បានចាត់តាំងសហ ការី ចំនួន ៣នាក់ ដឹកនាំដោយលោក **ស៊ិន ឃិន** ចុះទៅខេត្តតាកែវ ដើម្បីស្រាវជ្រាវឯកសារភស្តុតាង សាក្សី ទាក់ទងអំពើឧក្រិដ្ឋកម្ម របបខ្មែរក្រហម ប្រល័យពូជសាសន៍ នៅខេត្តតាកែវ ។

## <u>ខេត្តតាកែវ</u>

ក្រុមស្រាវជ្រាវ បានទៅដល់ខេត្តតាកែវ នៅម៉ោង ៩:០០ ជួបអភិបាលរងទី២ ឯកឧត្តម **ឈិត សុខុន** យើងបានទំនាក់ទំនងការងារ បានជំរាបពីគោលបំណង សំណូមពរ ការងាររួចហើយ ខេត្តបាន ចេញឧទ្ទេសនាម លេខ ១៣៧ ៣នកក អោយយើងចុះទៅតាមបណ្តាស្រុក ៣ គឺ :

១- ស្រុកកោះអណ្តែត

២- ស្រុកគិរីវង្ស

៣- ស្រុកអង្គរបុរី

## I. <u>ស្រុកកោះអណ្តែត</u>

យើងបានទៅដល់ស្រុកកោះអណ្តែតនៅម៉ោង ១០:០០ យើងបានជួបលោកអភិបាលស្រុកឈ្មោះ **គិន ណែម** ។ ក្រុមយើងបានជំរាបពីគោលបំណងសំណូមពរនៃការស្រាវជ្រាវរបស់យើង ។ ស្រុក នោះចម្ងាយពីសាលាខេត្តតាកែវ ៤០គីឡូម៉ែត្រ ។

**ទីតាំងស្រុក** ៖ ឋិតនៅខាងត្បូងខេត្ត ប៉ែកខាងកើត ។ សម័យ **ប៉ុល ពត** ភូមិភាគនិរតី តំបន់ ៣ ស្រុក ១០៨ ។

**ព្រំប្រទល់ស្រុក**

- ខាងជើង ទល់នឹងស្រុកទ្រាំង និងស្រុកបូរីជលសារ
- ខាងត្បូង ស្រុកគីរីវង្ស និងប្រទេសវៀតណាម
- ខាងលិច ស្រុកទ្រាំង និងស្រុកគីរីវង្ស
- ខាងកើត បុរីជលសារ
- ស្រុកនោះមាន ៦ឃុំ៦៦ភូមិ
- មាន ៣០០០ គ្រួសារ មនុស្ស ៤០០០០ នាក់ជាង ។
- មុខរបរប្រជាជន ធ្វើស្រែ ស្រែប្រាំងសំខាន់ មុខរបរគួបផ្សំ នេសាទត្រី ។ ស្រុកនោះជាតំបន់ លិចទឹក ។

⊗ **ពត៌មានអភិបាលស្រុក**

\+ **ទីតាំងប្រល័យពូជសាសន៍**

1 ។ **ទីតាំងសម្លាប់**

- **ទួលតាឃ្មោក**

ឋិតក្នុងភូមិរមិញខាងជើង ឃុំរមិញ ចម្ងាយពីសាលាស្រុក ២០០ម៉ែត្រ ។

2 ។ **ទីតាំងសម្លាប់**

- **ព្រៃសុខុន** (ព្រៃល្អាក់)

ឋិតក្នុងភូមិស៊ីស្វា ឃុំផ្លាប្រជុំ ចម្ងាយពីសាលាស្រុក ៩គីឡូម៉ែត្រ

ក្រៅពីទីតាំងធំៗទាំងពីរនេះ មានកន្លែងសម្លាប់ខ្លះៗទៀត តិចតួច ១នាក់ ២នាក់ រាយប៉ាយតាម បណ្តាឃុំនានា សម្លាប់រាយប៉ាយ គ្មានរណ្តៅ គួរអោយកត់សំគាល់ឡើយ ។

3 - **ទីតាំងសម្លាប់ ទួលក្រសាំងអែម**

- ភូមិចំបក់អែម ឃុំរមិញ

**ម៉ោង ១២:១៥នាទី**

**ទីតាំងសម្លាប់ ទួលតាឃ្មោក**

យើងបានចុះទៅទីតាំងសម្លាប់ ទួលឃ្មោក នោះឋិតក្នុងភូមិរមិញខាងជើង ឃុំរមិញ ស្រុកកោះ អណ្តែត បានជួបលោកមេភូមិ **កៅ ឆេង** ។ ទីតាំងនោះចម្ងាយពីសាលាស្រុកកោះអណ្តែត ២គីឡូ ម៉ែត្រ ។ ទីតាំងនោះ មានដីទួលខ្ពស់ មានត្រពាំងមួយ កន្លែងសម្លាប់ជុំវិញភ្លឺត្រពាំង ។

- **ពត៌មានពីលោកមេភូមិ កៅ ឆេង**

លោក **កៅ ឆេង** មុនសម័យ **ប៉ុល ពត** ក្រោយសម័យ **ប៉ុល ពត** ក្នុងសម័យ **ប៉ុល ពត** នៅភូមិរមិញនោះ រហូតទល់ឆ្នាំ១៩៧៩ ។ គាត់ជាប្រជាជននៅមូលដ្ឋាននោះ គាត់បានប្រាប់ យើងថា គាត់ឃើញពួកខ្មែរក្រហម **ប៉ុល ពត** យកមនុស្សមកសម្លាប់ទួលឃ្មោកពិតប្រាកដមែន គាត់ឃើញគេចងបណ្តើរជនរងគ្រោះទាំងខ្សែៗ មានពេលខ្លះ ២នាក់ ៣នាក់ ឬ ៤នាក់ ។ គាត់ឃើញគេវះ មនុស្សយកប្រមាត់ នាពេលនោះ ។

**ប្រភេទជនរងគ្រោះ**

- ប្រជាជន ១៧ មេសា អ្នកជំលៀសចេញពីទីក្រុងនានា
- ប្រជាជន មូលដ្ឋាន (ប្រជាជនចាស់)
- ពួកកម្មាភិបាលខ្មែរក្រហម (ពួកអ្នកខុសឆ្គង)
- អ្នកខុសឆ្គង នៅបណ្តាឃុំនានា
- ខ្មែរក្រហមបានសម្លាប់ប្រជាជននៅឆ្នាំ ១៩៧៦-៧៧-៧៨ ។

- **អំពីរណ្តៅសាកសព**

យើង និងសាក្សីបានពិនិត្យរណ្តៅសាកសពដែលនៅសេសសល់ និងគិតទៅតាមរណ្តៅសរុប ពី ៤០ ទៅ ៥០ ។ ក្នុងនោះគិតទាំងរណ្តៅតូច ធំ ទំហំ ២ម៉ែត្រ បួនជ្រុង ជំរៅពី ១,៥០ម៉ែត្រ ទៅ ២ម៉ែត្រ ។

អ្នកស្លាប់គិតសរុប ២៧៥នាក់ ទៅ ២៨០នាក់ សាក្សីនៅទីតាំងនេះមាន ២នាក់

សាក្សីបន្ថែមថា បើពួកឃាតករ ជីករណ្ដៅបានចំនួន ១០គ្រួសារ ២០គ្រួសារ យកតាមរណ្ដៅដែល ជីកនោះ ។ សាក្សីបានទៅរកក្របីគាត់ ឃ្វាលក្របី ឃើញគេសម្លាប់ គេបំរុងសម្លាប់គាត់ ប៉ុន្តែអង្វរគេបាន ព្រោះមានពួកវាម្នាក់ស្គាល់គាត់ ។

- **អំពីរណ្ដៅ**

រណ្ដៅធំៗណាស់ សាក្សីបានប្រាប់យើងថា មានរណ្ដៅ៤ ទំហំ ១០ម៉ែត្របួនជ្រុង ជំរៅ ២ម៉ែត្រ សម្លាប់ពេញៗទាំងអស់ រណ្ដៅទីនោះលប់បាត់អស់ហើយ ប៉ុន្តែឆ្អឹងអាចនៅសល់ក្នុងដី ។ គ្មានអដ្ឋិធាតុគំ កល់ទុកទេ ។ (រណ្ដៅរាប់មិនអស់)

**ចំនួនអ្នកស្លាប់**

សាក្សីបានប៉ាន់ស្មានថា ប្រហែលពី ១២០០០នាក់ ទៅ ១៥០០០នាក់ ។

**បញ្ហាក់** ទីតាំងនោះមិនមែនគុកទេ គឺកន្លែងសម្លាប់ដ៏ធំ ឆ្នាំ១៩៧៥ សម្លាប់ពួកអ្នក ១៧មេសា អ្នកជំលៀសចេញពីទីក្រុងនានា ពិសេសទាហ៊ាន គ្រួសារទាហ៊ាន និងពួកខ្មែរកម្ពុជាក្រោម ដែលគាត់បំរុង ទៅស្រុកកំណើតគាត់វិញ ត្រូវពួកខ្មែរក្រហមសម្លាប់គ្មានសល់ ១នាក់ទេ ។

ឯកសារគួបផ្សំ និងលំអិត យើងសំភាសន៍សំដីសាក្សីផ្ទាល់ ទាំង ៣នាក់ ថតសាក្សីទុកថតទីតាំង សម្លាប់ ។

ថ្ងៃទី១២-៨-៩៨

## II. ស្រុកគីរីវង្ស

យើងធ្វើដំណើរតាមផ្លូវជាតិលេខ ....... ពីសាលាខេត្ត ទៅដល់សាលាស្រុកម៉ោង ៨ព្រឹក ។ នៅទី នោះយើងបានជួប :

១- លោក **ឆិន សុខខៃ** អភិបាលស្រុក

២- លោក **លីវ សំអឿន** ប្រធានការិយាល័យវប្បធម៌ស្រុក

- **ទីតាំងសាលាស្រុក ឬទីតាំងស្រុក**

ឋិតនៅខាងត្បូងខេត្តតាកែវ ជាប់ព្រំប្រទល់ប្រទេសវៀតណាមខាងត្បូង ។ ចម្ងាយពីសាលាខេត្ត ៤០គីឡូម៉ែត្រ ។ សម័យ **ប៉ុល ពត** ភូមិភាគនិរតី តំបន់ ៣

<u>ព្រំប្រទល់ស្រុក</u>

- ខាងជើង ទល់នឹងស្រុកទ្រាំង
- ខាងត្បូង ប្រទេសវៀតណាម
- ខាងលិច ខេត្តកំពត
- ខាងកើត ស្រុកកោះអណ្តែត
- ស្រុកនោះមាន ១២ឃុំ ១១៤ភូមិ ប្រជាជន ១៧៩៦៧ គ្រួសារមានមនុស្ស ៩១៦៤៦នាក់ ។
- មុខរបរប្រជាជន ធ្វើស្រែ និងចំការ ជីកឥដ្ឋ ថ្មបាយក្រៀម និងដំណាំម្រេច ដីថ្មី ។

\+ **<u>ទីតាំងប្រល័យពូជសាសន៍</u>**

នៅស្រុកគីរីវង្ស មានទីតាំងធំតែមួយ គឺវត្តព្រះធាតុ ។ ឯក្រៅពីនោះមានតិចតួចនៅគ្រប់ឃុំ មិនមែនប្រមូលផ្តុំទេ ។ ពីព្រោះស្រុកនោះខ្មែរក្រហមមិនអោយប្រជាជននៅជិតព្រំដែនវៀតណាមទេ
ពួកវាខ្លាចប្រជាជនលួចរត់ទៅប្រទេសវៀតណាម ដូច្នេះវាអោយប្រជាជនមកនៅក្នុង១វិញ ។ យើងមាន ឯកសារដែលវប្បធម៌បានផ្តល់អោយ១ច្បាប់ រក្សាទុកជូនភ្ជាប់ទុកឯកសារ ។

- **<u>ការចុះទៅដល់ទីតាំងប្រល័យពូជសាសន៍</u>**

ម៉ោង១០:០០ យើងធ្វើដំណើរទៅដល់ទីតាំងសន្តិសុខ និងគុក កន្លែងសម្លាប់វត្តព្រះធាតុ ចម្ងាយពីសាលាស្រុក ២០គីឡូម៉ែត្រ។ ធ្វើដំណើរពីសាលាស្រុកដល់ភូមិពេជសារ ៨គីឡូម៉ែត្រ បត់ឆ្វេងដៃចូល ជ្រៅ ១២គីឡូម៉ែត្រ ទៅដល់ទីតាំងវត្តនោះ ។ ទីតាំងនេះឋិតក្នុងភូមិក្បាលដំរី ឃុំគោកព្រីង ស្រុកគីរីវង្ស ខេត្តតាកែវ ។

ទីតាំងនោះសន្តិសុខ និងគុក ទីតាំងសម្លាប់ក្បែរនោះតែម្តង ជាទីតាំងដ៏ធំតែមួយរបស់ស្រុកគីរី វង្ស ពួកខ្មែរក្រហមកសាងឆ្នាំ១៩៧៥ រហូត ១៩៧៩ ។

សាលាបុណ្យ ទទឹង ១២ម៉ែត្រ បណ្តោយ ១៥ម៉ែត្រ ធ្វើពីបេតុង គេយកធ្វើគុក កស្តុតាងខ្មោះនៅ ទល់សព្វថ្ងៃ អដ្ឋិធាតុរក្សាទុកនៅទីនោះខ្លះៗដែរ គាស់១៩៨៤ មានច្រើន ប៉ុន្តែខ្វះការថែទាំ គោស៊ីអស់ ។

ផ្ទះពួកសន្តិសុខ ស្នាក់នៅ កុដិព្រះសង្ឃ ២ ។ ទីតាំងសម្លាប់មុខព្រះវិហារ ក្នុងបរិវេណវត្ត ជាង របង ។ នៅទីនោះក្រុមយើងបានស្វែងរកសាក្សីបាន ៣នាក់ ក្នុងនោះអ្នកធ្លាប់ជាប់គុក ១នាក់ នៅទីនោះ បាននៅរស់ ហើយគាត់ព្រមធ្វើសាក្សី ។

សាក្សីទាំងនោះ មានឈ្មោះដូចតទៅ ៖

១- **លី ថុន** អាយុ ៥៥ឆ្នាំ ធ្លាប់ជាប់គុកនៅទីតាំងនោះ ១ឆ្នាំ ។

២- លោកតា **ជាក សាន** អាយុ ៧៤ឆ្នាំ ។

៣- លោកតា **អ៊ុក យ៉ាន** អាយុ ៦៥ឆ្នាំ ។

សាក្សីទាំង ៣នាក់ នោះនៅភូមិក្បាលដំរី ឃុំគោកព្រិច ស្រុកគីរីវង្ស ខេត្តតាកែវ សម័យ **ប៉ុល ពត** ក៏នៅភូមិ ឃុំ ស្រុក ខេត្ត ដូចសព្វថ្ងៃដែរ ខ្លះមានតួនាទីក្នុងសហករណ៍ **ប៉ុល ពត** និងខ្លះឡើង ត្នោត អោយពួកឃាតករ គឺសន្តិសុខ វត្តព្រះធាតុនោះតែម្តង ។

- ***<u>ពត៌មានពិតពីសាក្សី</u>***

សាក្សីបានអះអាងថា គាត់បានឃើញផ្ទាល់ភ្នែក គេវៃស្នូរចម្លើយម្តងៗស្រែកដូចជាសត្វធាតុ គេ សម្លាប់ម្តងៗ អស់ ៥០នាក់ យកចូលវិញ ៥០នាក់ រាល់ៗពេលដែលគេសម្លាប់រួច ពួកខ្មែរក្រហមបានដឹក រទេះសេះ ឃុំជិត ខ្លះដឹកឡាន តូចៗ ។

គុកសន្តិសុខនេះ ពួកគេប្រមូលជនរងគ្រោះពីបណ្តាភូមិ ឃុំ សហករណ៍ នានា ដំបូងពួក ១៧ មេសា គ្រប់ស្រទាប់ ជំលៀសពីទីក្រុង ប្រជាជនមូលដ្ឋាន និងពួកខ្មែរក្រហមផងដែរ ។ សាក្សី **លី ថុន** បានឃើញរថយន្តហ្ស៊ីប មួយគ្រឿងមានមេខ្មែរក្រហមនោះមានកាំភ្លើងខ្លី មានអ្នកការពារ ឡានមកដល់ ពួកសន្តិសុខភ្ជង់ដកកាំភ្លើងខ្លីទាំងអស់ រួចបញ្ចូលគុក វៃខ្នោះដៃ ជើង រួចសម្លាប់ពេលយប់ ។ គាត់ថា គេ សម្លាប់ចំរុះ មានក្មេងៗក៏មាន ចាស់ ស្ត្រី រយះពេលសម្លាប់ពី ១៩៧៥ ទល់

ឆ្នាំ១៩៧៩ ។ អ្នកជាប់គុក ទីនោះមិនបញ្ចេញបណ្ដើរអោយធ្វើការទេ ពេលយកទៅសម្លាប់ដើរស្ទើរមិនរួច ស្គមណាស់ទៅហើយ ។

ទិដ្ឋភាពក្នុងគុក ខ្នោះតំរៀប ៣ជួរ ដាក់ជនរងគ្រោះ ដើងចូលគ្នាក្បាលចេញដាក់ជើងតែមួយៗទេ ១ជួរៗ ពី ៦០នាក់ ទៅ ៨០នាក់ ។

សាក្សីបន្ថែមប្រាប់យើងថា នៅឆ្នាំ១៩៨៤ គាស់អដ្ឋិធាតុបានឆ្អឹងលលាដ៍ក្បាល ៣៥០ក្បាល ប៉ុន្តែ មិនទាន់អស់ទេ ។ គាត់រួមគាស់ផ្ទាល់ពេលនោះ ។

- **ចំនួនរណ្ដៅសាកសព**

រណ្ដៅទាំងតូចធំមានពី២ម៉ែត្របួនជ្រុង ជំរៅ១,៥០ម៉ែត្រ ទៅ ២ម៉ែត្រ ខ្លះធំ ៥ម៉ែត្របួនជ្រុង សម្លាប់គរតាមចំនួន បើសម្លាប់ម្ដង ១០នាក់ រណ្ដៅ១០នាក់ បើរណ្ដៅណាធំ កប់មិនពេញសម្លាប់បន្ថែម ដាក់ពីលើ ។ សួរចម្លើយរួចយកទៅសម្លាប់ ។

ដូច្នេះតាមសំដីសាក្សីរាប់រណ្ដៅក្លាមៗ ក្រោយឆ្នាំ១៩៧៩ ឃើញប្រហែលពី ២០០រណ្ដៅ ទៅ ៣០០រណ្ដៅ ។ ដូច្នេះអ្នកស្លាប់ ប៉ាន់ស្មានរាប់ម៉ឺននាក់ សាក្សី **លី ឌុន** គាត់ថា ប្រហែលពី ១២០០០នាក់ ទៅ ១៥០០០នាក់ ឬ ១៧០០០នាក់ ។

**ជនរងគ្រោះ**

ពួកខ្មែរក្រហម មិនទុកព្រំដែនទេ ពួកគេបញ្ជូនទៅជ្រៅៗអស់ហើយ ពិសេសបណ្ដាឃុំនានា នៅ ស្រុកព្រៃកប្បាស ។ ដូច្នេះយើងបានពត៌មានពីអភិបាលស្រុកថា គ្មានទីតាំង ប្រល័យពូជសាសន៍ទេ ។

## សេចក្ដីសន្និដ្ឋាន

ខ្ញុំយល់ឃើញថា បណ្ដាស្រុកទាំង៣ ដែលក្រុមយើងចុះនេះ ជាស្រុកនៅជាយដែនជាប់ព្រំប្រទល់ ប្រទេសវៀតណាមខាងត្បូង ដូច្នេះជនរងគ្រោះ ឬ ប្រជាជននាសម័យនោះ ពួកខ្មែរក្រហម មិនទុកនៅព្រំ ដែនទេ ពួកគេច្រើនបញ្ជូនទៅក្នុងប្រទេស អោយឃ្លាតពីព្រំដែន ។ជនរងគ្រោះក៏ដូច្នេះដែរ មិនដាក់នៅ ជាយដែនទេ ។ ដូច្នេះការសម្លាប់មានតិចទេ ។ ជាការពិតស្រុកកោះអណ្ដែត សម្លាប់ព្រៃសុខុនច្រើន យើង ទទួលស្គាល់ថា ពិតមែន ពីព្រោះសម្លាប់ នៅឆ្នាំ១៩៧៥

ពេលបែកទីក្រុងដំលៀសចេញ ពីទីក្រុង ហើយ ខ្មែរកម្ពុជាក្រោម ខ្មែរក្រហមមិនទុកទេ ។ ហើយពួកនេះភាគច្រើន ជាទាហ៊ានផង ។

យើងហៅស្របថា សាក្សីនិមួយៗរាយការណ៍គឺជាការពិត យកជាការបានព្រោះគាត់ជាអ្នកនៅជាមួយខ្មែរក្រហមនាសម័យនោះ ហើយខ្លះទៀតធ្លាប់ជាប់គុកផង ។ ដូច្នេះការស្រាវជ្រាវ ក្រុមយើងធ្វើ រយៈពេលខ្លីក៏មែនពិត ប៉ុន្តែយើងបានទៅដល់ទីតាំងប្រល័យពូជសាសន៍ផ្ទាល់ ឃើញជាក់ស្តែងនូវភស្តុតាង ដូចជាអដ្ឋិធាតុ ខ្នោះដែក នៅសល់វត្តព្រះធាតុ ។ ការងាយស្រួលនៅតាមស្រុកនាពេលនោះគ្មានពួកខ្មែរ ក្រហមទេ នៅតាកែវ ព្រៃវែង ។ ការលំបាក បារម្ភ ផ្លូវលំបាក រអិល និងអាចមានភេរវកម្ម បើសិនមាន ឬ ជួបប្រទះ ។ (បារម្ភពេលយប់) បើសិនយើងមានការខក ដោយឧបសគ្គ ។ ប៉ុន្តែវិធានការណ៍យើង ត្រៀមជានិច្ច ពុះពារគ្រប់យ៉ាង ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី១៦ ខែ សីហា
ឆ្នាំ១៩៩៨
អ្នកសរុបរបាយការណ៍
ប្រធានក្រុមស្រាវជ្រាវ

**ស៊ិន ឃិន**